**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ០១.២០៦/០៧  គ.ជ.ប.អគ្គ.ពស**  ភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧

# សន្និសីទសារព័ត៌មាន ផ្សព្វផ្សាយលទ្ធផលបណ្តោះអាសន្ននៃការចុះបញ្ជីបេក្ខជន ការចែកប័ណ្ណព័ត៌មាន និងការបង្ហាញគំរូទម្រង់សន្លឹកឆ្នោត

នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប) បានរៀបចំសន្និសីទសារព័តិមាន ផ្សព្វផ្សាយអំពីលទ្ធផលនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ការចែកប័ណ្ណព័តិមានអ្នកបោះឆ្នោត និងការបង្ហាញគំរូទម្រង់សន្លឹកឆ្នោត សម្រាប់យកទៅប្រើក្នុងពេលបោះឆ្នោត ។

ឯកឧត្តម ហាវ៉ាណេ ស៊ីរិល័យ សមាជិក គ.ជ.ប បានមានប្រសាសន៏ក្នុងសន្និសីទនោះថា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ មានគណបក្សនយោបាយចំនួន ១២ បានចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ហើយគណបក្សទាំងនោះមាន គណបក្សប្រជាជនកម្ពុជា បានដាក់បេក្ខជនឈរឈ្មោះ នៅឃុំ សង្កាត់ទាំង ១.៦២១ គណបក្សហ៊្វុនស៊ិនប៉ិច ចំនួន ១.៤៦០ ឃុំ សង្កាត់ គណបក្សសម រង្ស៊ី ចំនួន ១.៥៩៦ ឃុំ សង្កាត់ គណបក្សនរោត្តម រណឫទ្ធិ ចំនួន ១.៤៣១ ឃុំ សង្កាត់ គណបក្សប្រជាធិបតេយ្យខ្មែរ ចំនួន ១១៤ ឃុំ សង្កាត់ គណបក្សរណសិរ្សសង្គមជាតិនិយម ចំនួន ១០០ ឃុំ សង្កាត់ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ចំនួន ២៥ ឃុំ សង្កាត់ គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ ចំនួន ១៣៣ ឃុំ សង្កាត់ គណបក្សប្រជាជាតិខ្មែរ ចំនួន ៨ ឃុំ សង្កាត់ គណបក្សសង្គមប្រជាធិបតេយ្យ ចំនួន ១០ ឃុំ សង្កាត់ គណកបក្សចំរើននិយមខ្មែរ ចំនួន ១ ឃុំ និងគណបក្សសង្គមខ្មែរនិយម ចំនួន ១៣ ឃុំ សង្កាត់ ។

ជាមួយគ្នានេះដែរ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប ក៏បានមានប្រសាសន៏ទាក់ទងនឹងការផ្តល់ប័ណ្ណព័តិមានអ្នកបោះឆ្នោតលើកទី២ដែរថា គ.ជ.ប មានគម្រោងចែកចាយប័ណ្ណព័តិមាននេះចាប់ពីថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០០៧ ដល់ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០០៧ ហើយការចែកលើកទី២គឺមានក្រុមចែកប័ណ្ណព័តិមាន ដែលសមាសភាពក្រុមចែកប័ណ្ណព័តិមាននេះតម្រូវឱ្យមាន សមាជិកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ជាប្រធាន សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ១រូប ឬច្រើនរូបជាសមាជិក តំណាងអង្គការមិនមែនរដ្ឋាភិបាល ១រូប ឬច្រើនរូបជាសមាជិក និងមេភូមិពាក់ព័ន្ធ ជាសមាជិក ។

ឯកឧត្តម អគ្គលេខាធិការ បានបន្ថែមទៀតថា គោលបំណងនៃការចែកប័ណ្ណព័តិមានអ្នកបោះឆ្នោតមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៧ ដើម្បីរំលឹកដល់ប្រជាពលរដ្ឋអំពីកាលបរិច្ឆេទ ពេលវេលានៃការបោះឆ្នោត លេខរៀង លេខកូដ ឈ្មោះ ទីតាំងការិយាល័យបោះឆ្នោត និងឯកសារសំរាប់យកទៅបោះឆ្នោត ។ ប័ណ្ណព័តិមាននេះ គ្រាន់តែជាការជូនព័តិមានដល់អ្នកបោះឆ្នោតម្នាក់ៗ ដើម្បីអញ្ជើញទៅបោះឆ្នោត មិនអាចយកទៅប្រើជំនួសឯកសារបញ្ជាក់អត្តសញ្ញាណសាមីខ្លួនបានឡើយ ។ បើប្រជាពលរដ្ឋមិនទាន់បានទទួលប័ណ្ណព័តិមានក្នុងអំឡុងពេលចែកប័ណ្ណ អាចទំនាក់ទំនងនៅគឃ/សប ដែលស្ថិតនៅក្នុងឃុំ សង្កាត់ដែលខ្លួនរស់នៅ ។ ទោះបីមិនបានទទួលប័ណ្ណព័តិមាននេះក៏ដោយ ប្រជាពលរដ្ឋដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតក៏អាចទៅបោះឆ្នោតបានដែរ ។

លោក ហ៊ី រ៉ុង ប្រធាននាយកដ្ឋានប្រតិបត្តិការ គ.ជ.ប ក៏បានផ្សព្វផ្សាយអំពីគំរូទម្រង់សន្លឹកឆ្នោតដល់តំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័តិមានជាតិ អន្តរជាតិ ។ លោកបានបញ្ជាក់ថា គ.ជ.ប បានអញ្ជើញតំណាងគណបក្សនយោបាយ ពិនិត្យមើលគំរូទម្រង់សន្លឹកឆ្នោតរួចហើយ កាលពីថ្ងៃទី ១៩-២០ ខែ មករា ឆ្នាំ ២០០៧ ហើយគំរូទម្រង់សន្លឹកឆ្នោតនេះមាន ៣ប្រភេទ គឺប្រភេទក្រដាស A4, F4 និង វែងជាង F4 ។

ពាក់ព័ន្ធនឹងសន្លឹកឆ្នោតនេះដែរ តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ចង់ឱ្យ គ.ជ.ប បង្ហាញតម្លាភាពនៃការបោះពុម្ពសន្លឹកឆ្នោត ការគូសលើសន្លឹកឆ្នោតចាត់ទុកគំនូសមួយណាជាបានការ ។

ឯកឧត្តម អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៏ថា នៅថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០០៧ គ.ជ.ប នឹងអញ្ជើញតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័តិមាន ដើម្បីចូលរួមពិនិត្យមើលរោងពុម្ពដែលត្រូវបោះពុម្ពសន្លឹកឆ្នោតនោះ ។ ចំពោះគំនូសនៅលើសន្លឹកឆ្នោតដែលចាត់ទុកជាបានការ ឬមិនបានការ គ.ជ.ប នឹងបើកវគ្គបណ្តុះបណ្តាលរួមគ្នាមួយ ដើម្បីកំណត់ឱ្យបានច្បាស់អំពីនីតិវិធី នៃការគូសសន្លឹកឆ្នោត ។

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង : ទូរស័ព្ទលេខ: ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៨** E-mail: necinfo@forum.org.kh,  Web-site : www.necelect.org.kh